# តើឯកសារអ្វីខ្លះដែលមាននៅក្នុងបញ្ជីឯកសាររបស់អង្គជំនុំជម្រះ
# បន្តការពិភាក្សាលើឯកសារ ក្នុងសំណុំរឿង០០២

ដោយ វ៉េនឌល ឌីហ្សាលកូ

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

កែសម្រួលដោយ ហ៊ុយ សម្ផស្ស

**«ខ្ញុំបានលះបង់ខ្លួនខ្ញុំ ខ្ញុំបានលះបង់អ្វីៗគ្រប់យ៉ាងដើម្បីបុព្វហេតុជាតិ» នួន ជា ។**

នៅថ្ងៃព្រហស្បត្តិ៍ ទី១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បន្តសំណុំរឿង០០២ ប្រឆាំងទៅនឹងអតីតមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម នួន ជា, អៀង សារី និង ខៀវ សំផន។ នៅក្នុងអំឡុង៣ថ្ងៃ នៃដំណើរការនីតិវិធីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងនូវឯកសារភស្តុតាងនានា ដោយដាក់ឯកសារទាំងនោះជូនអង្គជំនុំជម្រះនិងអានឡើងនៅក្នុងសវនការ ។ ដំណើរការរឿងក្តីថ្ងៃនេះគឺស្តីអំពីការសរុបផ្នែកមួយដំណើរការសវនការសំណុំរឿង០០២ ដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រជាមូលដ្ឋាននៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ ។ អំឡុងពេលនេះមានព្រឹត្តការណ៍សំខាន់ៗនានាដូចជា ការបង្កើតចលនាបក្សកុម្មុយនីស្តកម្ពុជា និងការបង្កើតបក្សនយោបាយរបស់បក្សកុម្មុយនីសកម្ពុជានិងសង្គ្រាមស៊ីវិលរវាងខ្មែរក្រហម និងរដ្ឋាភិបាល លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិកពីឆ្នាំ១៩៧០ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមដណ្តើមបានអំណាចគ្រប់គ្រងប្រទេសកម្ពុជាទាំងមូល ។

## នួន ជា ឆ្លើយតបទៅនឹងឯកសារនានាដែលបានដាក់ជូនអង្គជំនុំជម្រះ

កិច្ចដំណើរការនីតិវិធីថ្ងៃនេះ ចាប់ផ្តើមដោយអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យជនជាប់ចោទ នួន ជា បញ្ចេញយោបល់ទាក់ទងទៅនឹងឯកសារនានាដែលបានដាក់ជូនអង្គជំនុំជម្រះកាលពីពេលបីថ្ងៃមុន ។ ជាដំបូង នួន ជា ឡើងប្រាប់អង្គជំនុំជម្រះថា លោកមានការលំបាកនឹងអានរាល់ឯកសារដែលបានដាក់ជូនដោយភាគីនានាដោយសារ«វ័យចំណាស់»របស់គាត់ ។ នួន ជា បានស្នើសុំឲ្យការផ្ទៀងផ្ទាត់របស់

ខ្មែរអាត់សម្ភាសន៍ជាមួយគាត់ និងព្រមទាំងបដិសេធថារាល់បទសម្ភាសន៍ទាំងនោះមិនមែនជាការពិត ។ នួន ជា បដិសេធ ជាពិសេសថាធ្លាប់បានផ្តល់បទសម្ភាសន៍ជាភាសាអង់គ្លេស ដោយអះអាងថា «ខ្ញុំបានលះបង់ ខ្ញុំបានលះបង់អ្វីៗគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិ និងមិនដែលធ្លាប់បានធ្វើបទសម្ភាសន៍ជាភាសាអង់គ្លេសទេ» ។ បន្ទាប់មក នួន ជា ស្នើក្សាសិទ្ធិក្នុងការបញ្ចេញយោបល់ពីទស្សនាវដ្តី ទង់បដិវត្ត ដរាបណាអង្គជំនុំជម្រះមិនទាន់សម្រេចលើសុក្រិត្យភាពរបស់វា ។ លោកបានកត់សម្គាល់ថាលោកបានលឺពីកិច្ចសហការតាមរយៈការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកលើកឡើងថាមាន«បំណងល្អ»សហការជាមួយអង្គជំនុំជម្រះ ។ ទោះជាយ៉ាងនេះក្តី នួន ជា «ទទូច»អង្គជំនុំជម្រះឲ្យធ្វើការ«ផ្ទៀងផ្ទាត់»ពីសុក្រិត្យភាពរាល់ឯកសារនានា ដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានលើកឡើងថា លោកមានបំណងឲ្យរាល់បញ្ហាសុក្រិត្យភាពត្រូវបាន«ពិចារណាឲ្យបានត្រឹមត្រូវ»មុននឹងបន្តដំណើរការរឿងក្តី ។ នួន ជា ក៏បានចោទប្រកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា មានភាពលម្អៀងប្រឆាំងនឹងរូបខ្លួន និងកត់សម្គាល់ឃើញថាការចោទពីភាពលម្អៀងនេះ ដោយយោងទៅលើបុគ្គលិករបស់ការិយាល័យនេះ កាលពីឆ្នាំ២០១១ ។ លោកក៏បានបន្ថែមទៀតផងដែរថា នេះ«គឺពិតជាជាក់ច្បាស់ណាស់»ថាការអះអាងដោយព្រះរាជអាជ្ញាដែលថាឯកសារនានាគឺជាឯកសារដើមគឺជាការអះអាងបម្រើឲ្យផលប្រយោជន៍ខ្លួនឯង ដូច្នេះហើយអង្គជំនុំជម្រះគួរតែសម្របសម្រួលរាល់ការទទួលបាននូវឯកសារដើមនានាសម្រាប់គ្រប់ភាគី ។ នួន ជា លើកឡើងថា នេះជារឿងសំខាន់ណាស់ដែលលោកអាចនឹងទទួលបាននូវឯកសារច្បាប់ដើមនានាដើម្បី«អាចឲ្យលោកចូលរួមឲ្យមានប្រសិទ្ធិភាពក្នុងបេសកម្មស្វែងរកការពិតសម្រាប់ប្រទេសជាតិទាំងមូល» ។ បន្ទាប់មក នួន ជា និយាយថា សាក្សីមួយចំនួន ដែលបានធ្វើសក្ខីកម្មក្នុងសំណុំរឿង០០២នេះ«មិនមានប្រយោជន៍» និងបង្ហាញចំណាប់អារម្មណ៍ថា ពួកគេ«មិនសូវជាចូលរួម»ជាមួយដំណើរការតុលាការក្នុងពេលសាកសួរទេ ។ លោកក៏បានលើកឡើងផងដែរថា សាក្សីដែលខាងមេធាវីការពារស្នើសុំមិនដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះទេ ។ នួន ជា បានលើកឡើងថា ដោយសារតែគ្មានវត្តមានអ្នកទាំងនេះនឹងនាំឲ្យនៅតែមានការខ្វះចន្លោះភស្តុតាង ដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្រជាមូលដ្ឋាន នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយអះអាងថា «សាធារណជនមិនបានត្រូវគេផ្តល់ព័ត៌មាន»គ្រប់គ្រាន់ពីអ្វីដែលបានកើតឡើងក្នុងកំឡុងពេលនោះ ។ នួន ជា លើកឡើងថា «យើងចាប់បានតែក្បាលក្រពើមិនបានខ្លួនទាំងមូលទេ» គាត់ក៏បានកត់សម្គាល់ពីអ្វីដែលគាត់ឃើញថា តុលាការមិនបានពិភាក្សាឲ្យបានគ្រប់គ្រាន់ ពីការទម្លាក់គ្រាប់បែករបស់អាមេរិកមកលើកម្ពុជា ដែលលោកអះអាងថា នឹង«បំផ្លាញ»ប្រជាជាតិខ្មែរនៅប្រទេស

កម្ពុជា ។ បន្ទាប់មក នួន ជា បានចោទព្រះរាជអាជ្ញាពីបទព្យាយាមបង្កើត«ប្រវត្តិសាស្ត្រមួយ ដែលមិនពេញលេញ» ។

ការរៀបរាប់កំណត់សម្គាល់របស់ នួន ជា ខៀវ សំផន និង អៀង សារី មិនបានផ្តល់យោបល់លើឯកសារនានាទេ ។ ប្រធានអង្គជំនុំជម្រះបានផ្តល់វេទិកាទៅឲ្យមេធាវីការពារក្តីមានមតិលើឯកសារនានា ។ មុនពេលផ្តល់វេទិកាទៅឲ្យសហសេវិករបស់គាត់ លោក អេង្រ្ទូ អឺអានូហ្សី ដើម្បីធ្វើការកត់សម្គាល់ ហ្សាសពើ ប៉ាវ មេធាវីនាំមុខនៃក្រុមការពារក្តីបានស្នើថា អង្គជំនុំជម្រះបានផ្តល់ពេលវេលាដល់ក្រុមការពារក្តី៤៥នាទី«ក្នុងចំណុចណាមួយ នៅពេលខាងមុខ»ក្នុងការសន្និដ្ឋាននានា ទាក់ទងនឹងប្រវត្តិសាស្ត្រទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលលោក នួន ជា ជឿថាមិនត្រូវបានបង្ហាញឲ្យជាក់ច្បាស់គ្រប់គ្រាន់ទេ ។

## ការភ័ន្តច្រឡំទាក់ទងនឹងថ្ងៃដែលប្រធានបទត្រូវពិភាក្សា

លោកប្រធានអង្គជំនុំជម្រះ និល ណុន បានកាត់ការថ្លែងរបស់ លោក ប៉ាវ អង្គជំនុំជម្រះបានកំណត់លើកបញ្ហានេះរួចហើយ ដោយកំណត់ការឆ្លើយតបរបស់ក្រុមមេធាវីការពារឲ្យបានម៉ត់ចត់ទៅលើការមានមតិលើឯកសារជាក់លាក់នានា ។ លោកប្រធានក៏បានបង្គាប់ឲ្យក្រុមមេធាវីការពារបង្ហាញរាល់ការ សន្និដ្ឋាននានាជូនអង្គជំនុំជម្រះរាល់ឯកសារនានាដោយយោងតាមនីតិវិធីនានា ។ លោកក៏បានឆ្លើយតបដោយសំអាងថា អង្គជំនុំជម្រះពឹងផ្អែកទៅលើការដាក់ជូនឯកសារជាលាយលក្ខណ៍អក្សរដែលនាំឲ្យមានបញ្ហាផ្សេងៗដល់តម្លាភាពរបស់តុលាការ ។ សារជាថ្មីម្តងទៀត លោកត្រូវបានកាត់ដោយលោកប្រធានចៅក្រមដែលបានរំឭកលោក ប៉ាវ ថា ការសម្រេចលើឯកសារនានា មេធាវីការពារក្តី នួន ជា មានបំណងដាក់ជូនអង្គជំនុំជម្រះអាចនឹងត្រូវដាក់ចេញនូវក្នុងពេលកំណត់ ។ លោក ប៉ាវ បន្ទាប់មកផ្តល់ឱកាសឲ្យលោក អៀនុហ្សី ធ្វើការដាក់ការសន្និដ្ឋានទាក់ទងនឹងភស្តុតាងលើទំនាក់ទំនងប្រពន្ធ័គ្រប់គ្រងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ជាបឋម លោក អៀនុហ្សី សន្និដ្ឋានថានៅកន្លែងដែលសាក្សីថ្លែងពិភាក្សាផ្ទាល់ពីសកម្មភាពរបស់ជនជាប់ចោទ ឬទៅលើបញ្ហាសំខាន់ផ្សេងៗដូចជាមានសាក្សីខ្លះដែលគួរតែត្រូវបានចូលរួមនៅតុលាការ បើចំហរមុនពេលសក្ខីកម្មដំបូងរបស់ពួកគេអាចត្រូវបានទទួលស្គាល់ ។ ការសន្និដ្ឋាននេះធ្វើឲ្យមានការបដិសេធពីខាងព្រះរាជអាជ្ញាដែលសំអាងថាការបដិសេធទាក់ទងនឹងសាក្សី មិនមែនជាប្រធានបទសម្រាប់ពិភាក្សានៅថ្ងៃនេះទេ ។ លោក អៀនុហ្សី ឆ្លើយតបដោយសង្កេតថា ឯកសារមួយក្នុងចំណោមឯកសារដែលបានរាយនាមមិនមែនជាប្រធានបទសម្រាប់ការពិភាក្សានៅថ្ងៃនេះទេ ។ ការថ្លែងរបស់សាក្សី មាស មុត ដែលអតីតមេបញ្ជាការនាវីករបស់ខ្មែរ

ក្រហម ដែលលោកថា «ដូចដែលយើងដឹងហើយថាជាជនសង្ស័យក្នុងសំណុំរឿង០០៣» ។ តាមការជជែកពិភាក្សាបន្ថែមខ្លះៗ និងការយល់ច្រឡំចំណោមភាគីនានា អង្គជំនុំជម្រះពន្យល់ដោយសង្ខេប ។ បន្ទាប់ពី ចៅក្រម ហ្វេនស៍ មានបំណងចង់បញ្ជាក់ពីខ្លឹមសារដែលរៀបចំសម្រាប់ជជែកពិភាក្សាក្នុងថ្ងៃនេះ ។ ទោះជាយ៉ាងនេះក្តី រាល់ភាគីហាក់ដូចជានៅតែឋិតនៅក្នុងភាពមិនច្បាស់លាស់មិនយល់ស្រប ទោះជាបន្ទាប់ពីមានសេចក្តីណែនាំរបស់ចៅក្រម ហ្វេនស៍ ក៏ដោយ ។ លោក អៀនុហ្សី បានលើកឡើងថា ក្រុមមេធាវីការពារក្តី នួន ជា បានរៀបចំខ្លួនរួចជាស្រេចនឹងពិភាក្សាទាក់ទងទៅនឹងការកែតម្រូវនូវបញ្ជីរាយនាមឯកសារដែលផ្តល់ជូនដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់ អ.វ.ត.ក ខណៈដែលព្រះរាជអជ្ញាបានបន្តលើកឡើងថា ការថ្លែងនានារបស់សាក្សីមិនមែនស្ថិតនៅក្នុងការពិភាក្សាក្នុងនីតិវិធីថ្ងៃនេះទេ ។

បន្ទាប់មក ក្រុមមេធាវីការពារក្តី អៀង សារី មៃឃើល ការណាវ៉ាស បានថ្លឹងថ្លែងលើបញ្ហានេះ ហើយបានលើកឡើងថា តាមមតិរបស់គាត់ រាល់ភាគីទាំងអស់បានរៀបចំនឹងពិភាក្សាពីការកែតម្រូវបញ្ជីរាយនាមឯកសារ៩៥ ដែលបានផ្តល់មកឲ្យភាគីដោយផ្នែករដ្ឋបាលនៃ អ.វ.ត.ក ។ បន្ទាប់មក គង់ សំអុន មេធាវីជាតិការពារក្តី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះមិនគួរអនុញ្ញាតឲ្យកែតម្រូវបញ្ជីឯកសារ ដោយមិនផ្តល់ឲ្យភាគីនូវពេលវេលាក្នុងការសិក្សាឯកសារទាំងនោះ និងរៀបចំដាក់ជូនការសម្រេចនានា ។ ដោយយោងតាមហេតុផលនេះ អង្គជំនុំជម្រះបានឈប់សម្រាកពេលព្រឹកលឿនជាងសព្វមួយម្តងដើម្បីគ្រងនឹងរកវិធីយ៉ាងណាដើម្បីដោះស្រាយការភ័ន្តច្រឡំនេះ ។ បន្ទាប់ពីសម្រាកមក ចៅក្រម ហ្សង់មាក ឡាវែន៍ ព្យាយាមបញ្ចប់ការភ័ន្តច្រឡំ ។ លោកចៅក្រម ដំបូងបង្ហាញថា តារាងរាយនាមឯកសារថ្មីបំផុតនេះមាន៩៥ឯកសារ និងលោកសង្កេតឃើញថា ឯកសារទាំងនេះអាចប្រហែលជាមានភាពមិនស្របគ្នាទៅនឹងសេចក្តីណែនាំដទៃមួយចំនួនទៀត ទាក់ទងនឹងថ្ងៃនីតិវិធីដោយយោងទៅតាមសក្ខីកម្មរបស់សាក្សី ។ លោកចៅក្រមបានរំឭកភាគីទាំងអស់ថា ទន្ទឹករង្វាល់មាត់ត្រូវបានកំណត់ទាក់ទងនឹងបញ្ហានេះក្នុងរឿងថាតើឯកសារនេះជាឯកសារដើមនិងអាចជឿជាក់បាននោះ ឬយ៉ាងណានោះ ។ បន្ទាប់មក លោកចៅក្រមបានផ្តល់វេទិកាទៅភាគីផ្តើការបញ្ចេញយោបល់បន្ថែមទៀត ។

## អៀ សារី ចេញពីសាលសវនការក្នុងម៉ោងពេលដូចសព្វដង

បន្ទាប់មក អង្គ ឧត្តម ក្រុមមេធាវីការពារក្តី អៀង សារី ងើបឈរឡើង និងបានស្នើសុំជាប្រចាំថ្ងៃថា ជនជាប់ចោទ អៀង សារី សុំលះបង់សិទ្ធិចូលរួមតាមដានសវនការនៅថ្ងៃនេះដោយសុំទៅតាមដានដំណើរការនីតិវិធីតាមប្រព័ន្ធសរទស្សន៍វិញ ។ ប្រធានអង្គជំនុំជម្រះបានអនុញ្ញាតនឹងសំណើនេះ

ហើយ អៀង សារី ត្រូវបានគេយកចេញពីសាលសវនការ ។ បន្ទាប់មក តំណាងព្រះរាជអាជ្ញាអន្តរជាតិ ហ្វាគុនី ឌេនេដ្ឋ បានងើបឡើង និងជំទាស់នឹងមេធាវីការពារប្រើឈ្មោះពិតប្រាកដ របស់សាក្សីសំខាន់ៗ ដោយឆ្លើយតបទៅនឹងរឿងនេះ ប្រធានអង្គជំនុំជម្រះ និល ណុន បង្គាប់ឲ្យភាគីទាំងអស់ប្រើអនាមិក? នៅពេលសំដៅទៅលើសាក្សីនានា និងបន្ទាប់មកផ្ទាល់វេទិកាទៅឲ្យក្រុមមេធាវីការពារផ្តល់មតិលើការតវ៉ាទៅលើឯកសារនានា ។

## មេធាវីការពារក្តី នួន ជា ជំទាស់ទៅលើឯកសារ៦ និងស្នើសុំការធ្វើសក្ខីកម្មរបស់លោក ហេនរី ឃីសីងចឺ

បន្ទាប់មក លោក អៀនុហ្វី បានអានពីចំណងជើងឯកសារប្រាំមួយដែល មេធាវីការពារក្តី នួន ជា ជំទាស់ជាពិសេស ។ ឯកសារទាំងនោះរួមមាន ៖

១. ការថ្លែងរបស់សាក្សី មាស មុត មេបញ្ជាការនាវិកខ្មែរក្រហម

២. សំបុត្រឆ្លើយតបពី ស៊ីវ ហេតឌើ ទាក់ទងនឹង អ៊ុក ប៊ុនឈឿន និង ស៊ុម ខា

៣. បតិចារឹកនៃបទសម្ភាសន៍ជាមួយ អ៊ុក ប៊ុនឈឿន ដោយ ហេតឌើ

៤. សំណេរដោយដៃបកប្រែនៃបទសម្ភាសន៍របស់ ប៉េន ឃៀនិន ជាមួយ អ៊ុក ប៊ុនឈឿន

៥. អត្ថបទសរសេរដោយប្រើកុំព្យូទ័រពីបទសម្ភាសន៍ដដែលជាមួយអ៊ុក ប៊ុនឈឿន

៦. បទសម្ភាសន៍ជាមួយ ជា ស៊ីម ហេង សំរិ កាលពីថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩១ ។

ដោយយោងទៅតាមឯកសារទាំង៦នេះ លោក អៀនុហ្វី ជំទាស់ទៅនឹងការប្រើរាល់ឯកសារទាំងនេះ ពីព្រោះរាល់បុគ្គលទាំងអស់មិនបានចាត់តាំងជាសាក្សីក្នុងបញ្ជីសាក្សីដោយអង្គជំនុំជម្រះទេ ។ លោកក៏សម្គាល់ផងដែរថា បុគ្គលទាំង៥នាក់នោះលើកលែងតែ មាស មុត ចេញ ត្រូវបានបដិសេធដោយចៅក្រមចេញបញ្ជាដោយ អ.វ.ត.ក មិនអាចស្នើជនទាំងនេះមកធ្វើសក្ខីកម្មក្នុងតុលាការបើចំហបានទេ ។ ចុងក្រោយ លោក អៀនុហ្វី ជម្រាបអង្គជំនុំជម្រះថា ក្រុមមេធាវីការពារក្តី នួន ជា នឹងធ្វើការដាក់ជូននូវការស្នើជាលាយលក្ខណ៍អក្សរទាក់ទងនឹងសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់សារព័ត៌មានវៀតណាមថា នួន ជា «ឃាតករ និងជាជនដៃដល់ម្នាក់នៃអំពើប្រល័យពូជសាសន៍» ។ ការថ្លែងនេះត្រូវបានកាត់ដោយលោកប្រធានចៅក្រម និងបានបង្គាប់លោក អៀនុហ្វី ថា មិនត្រូវលើកយករឿងដែលមិនជាប់ពាក់ពន្ធ័ ឬរឿងដែលបានសម្រេចរួមហើយមកនិយាយទេ ។ បន្ទាប់មក លោក អៀនុហ្វី ថ្លែងថា «លោកបណ្ឌិត ហេនរី ឃីសិនចឺ នឹងធ្វើដំណើរមក ក្នុងតំបន់នេះ នៅប៉ុន្មានខែទៀតនេះ» ហើយស្នើថា «ប្រហែលជាអង្គជំនុំជម្រះអាចពិចារណាថាតើគួរអញ្ជើញលោក

ចូលរួមក្នុងតុលាការប្តូរអត់» ។ លោកលើកឡើងថា លោក ឃីសិចី ពិតជាសាក្សីដ៏សំខាន់ម្នាក់«ក្នុងការបំភ្លឺ» នូវផ្នែកខ្លះនៃសវនការទាក់ទងនឹងមូលដ្ឋាននិងប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ ។

## មេធាវីការពារក្តី អៀង សារី ជំទាស់នឹងប្រភេទឯកសារជាក់លាក់មួយចំនួន

វេទិកាបានផ្តល់ជូនទៅមេធាវីការពារក្តី អៀង សារី ពិភាក្សាពីឯកសារ៩៥នៅក្នុងបញ្ជី ។ លោក កាណាវ៉ាស មេធាវីការពារក្តី អៀង សារី ជាដំបូងជំទាស់នឹងការប្រើពេលវេលាកំនត់ដែលបង្កើតដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដោយលើកឡើងថា ប្រសិនបើឯកសារនេះត្រូវប្រើនោះ អ្នកនិពន្ធឯកសារនេះត្រូវតែហៅមកធ្វើសក្ខីកម្ម ។ បន្ទាប់មកលោក កាណាវ៉ាស លើកឡើងថា ដោយ គ្មានការគាំទ្រណាមួយទៅនឹងការផ្សាយសក្ខីកម្មដោយផ្ទាល់ពី«មេកានិច» ពីរបៀបតើទូរលេខនានាបានត្រូវគេផ្សព្វផ្សាយទូទាំងប្រទេស នៅក្នុងសម័យខ្មែរក្រហមទេរាល់ឯកសារទូរលេខទាំងអស់គួរតែត្រូវបានដកចេញ ។ ប្រភេទឯកសារទី៣ដែលមេធាវីការពារក្តី អៀង សារី ជំទាស់គឺរាល់ឯកសារដែល ស្ទីវ ហេឌើ រៀបចំឡើងដោយលោកសំអាងថា ស្ទីវ ហេឌើ បានធ្វើការនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា មុនពេលប្តូរទៅធ្វើការឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតហើយដែលប្រហែលជាមានកំហុសឆ្គងក្នុងការបកប្រែនានាក្នុងឯកសារមួយចំនួន ដែលបានធ្វើការកត់សម្គាល់ក្នុងឯកសារមួយជាក់ស្តែង ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ការពីថ្ងៃមុន។ មេធាវីការពារក្តី អៀង សារី ក៏បានជំទាស់ទៅនឹងការប្រើពាក្យថា ឯកសារ«ឌុច» ដែលមានន័យថា ជាឯកសារនានាដែលបានមកពីសំណុំរឿង០០១ នៃ អ.វ.ត.ក និងការថ្លែងរបស់ជនជាប់ចោទក្នុងសំណុំរឿងនោះគឺ កាំង ហ្គេចអ៊ាវ ហៅឌុច ។ លោក ខាណាវ៉ាស អះអាងថា ប្រសិនបើការធ្វើសក្ខីកម្មរបស់ ឌុច ត្រូវប្រើនោះ ឌុច ត្រូវតែនាំមកតុលាការនិងធ្វើសម្បថក្នុងនាមជាសាក្សី ពីព្រោះអង្គជំនុំជម្រះសាលាដំបូងមិនទាន់រកឃើញថា ឌុច មិនទាន់បានធ្វើសម្បថនៅឡើយក្នុងការធ្វើសក្ខីកម្ម ក្នុងសំណុំរឿង០០១ ។ បន្ទាប់មក លោក កាណាវ៉ាស បញ្ជាក់សារជាថ្មីម្តងទៀតពីការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី ពីការប្រើចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម នៅគុកទួលស្លែង ។ លោកបានធ្វើការអះអាងផ្សេងទៀតថា ប្រសិនបើអង្គជំនុំជម្រះពិតជាប្រើចម្លើយសារភាពទាំងនោះមែន ត្រូវតែធ្វើការកំណត់ការប្រើប្រាស់ឯកសារទាំងនោះ ដោយយោងទៅតាមយុត្តាធិការអន្តរជាតិ ។ ក្រុមការពារបន្ទាប់មក បដិសេធទៅនឹងការប្រើបទសម្ភាសន៍របស់សាក្សីនានា ដែលមិនធ្វើឡើងដោយការិយាល័យចៅក្រមស៊ើបអង្កេត ដោយអះអាងថា បុគ្គលដែលសម្ភាសនោះមិនមានសមត្ថភាពជាអ្នកស៊ើបអង្កេតទេ ។ លោកក៏បានបន្ថែមទៀតផងដែរថា ប្រសិនបើបទសម្ភាសន៍ទាំងនេះត្រូវបានយកមក ប្រើនោះជនណាក្តីដែល

ធ្វើបទសម្ភាសន៍នេះត្រូវតែហៅឡើងមកធ្វើជាសាក្សី ។ បន្ទាប់មក លោក កាណាវ៉ាស បានផ្តល់ជាយោបល់លើភស្តុតាងជាវីដេអូដែលភស្តុតាងរបៀបនេះ ងាយស្រួលនឹងធ្វើការកែប្រែបំផុត ។ លោកបានទុកនាទីជូនទៅ អង្គជំនុំជម្រះកំណត់នូវនាទីដ៏សមរម្យនៃភស្តុតាងជាវីដេអូ ។ លោក ខណាវ៉ាស ជំទាស់សម្រាប់ការប្រើឯកសារដែលបានពីសេវាព័ត៌មានផ្សព្វផ្សាយអន្តរជាតិ រាយការណ៍ពីសំណុំរឿងពីព្រោះឯកសារទាំងនោះបង្កើតឡើងដោយភ្នាក់ងារស៊ើបអង្កេតសំងាត់របស់សហរដ្ឋអាមេរិក ។ លោក កាណាវ៉ាស បានថ្លែងថា ភ្នាក់ងារស៊ើបអង្កេតសម្ងាត់ជារឿយៗប្រាកដជាបានធ្វើការងារសំខាន់ ប៉ុន្តែក៏បញ្ជាក់ច្បាស់ថា "ទទួលបានព័ត៌មានដោយវិធីមិនសមស្រប និងព័ត៌មានខុស" ។ ដូច្នេះលោកមេធាវីស្នើទៅអង្គជំនុំជម្រះពិនិត្យពិច័យរបាយការណ៍ អេស.ប៊ី.អាយ. ដោយឯករាជ្យប្រសិនបើត្រូវយកឯកសារទាំងនោះមកប្រើ ។ ក្រោយមក លោក កាណាវ៉ាស បែរទៅបញ្ហារសើបនៃទស្សនាវដ្តី "ទង់បដិវត្តន៍" ។ លោកអះអាងថា ក្រុមមេធាវីការពារមិនបានព្យាយាមអះអាងថាទស្សនាវដ្តីទាំងនេះត្រូវបានបង្កើតឡើង ឬក៏អាចមិនសុក្រិត្យទេ ប៉ុន្តែស្នើថាសៀវភៅទាំងនេះត្រូវបានគេចាត់ទុកថា ជាភស្តុតាងនិងត្រូវតែ"ស្រាវជ្រាវដោយឡែក" ពីភាពត្រឹមត្រូវនៃខ្លឹមសារក្នុងសៀវភៅនោះ ។ លោកបានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះបានធ្វើការ"សវនការដ៏សំខាន់"មួយ ទទួលស្គាល់នូវការប្រើឯកសារដូចជា ទង់បដិវត្តនេះរួចហើយ ហើយលោកជម្រាបអង្គជំនុំជម្រះថា មេធាវីការពារក្តី អៀង សារី មិនមែនជំទាស់ទៅនឹងការប្រើចម្លងដែលបានធ្វើការផ្ទៀងផ្ទាត់នឹងឯកសារដើមនោះទេ ប៉ុន្តែក្រុមលោកគ្រាន់តែចង់ឲ្យមានការផ្ទៀងផ្ទាត់ខ្លឹមសារនានាទៅនឹងភស្តុតាងផ្សេងៗទៀត ។ លោក កាណាវ៉ាស ក៏បានស្នើថា ឯកសារមួយដែលសរសេរដោយនៅប្រទេសអាល្លឺម៉ង់ ត្រូវបានបកប្រែ និងក្រុមការពារអនុញ្ញាតឲ្យបញ្ចេញយោបល់ឬជំទាស់ទៅនឹងឯកសារនេះបន្ទាប់ទៀត ។ ដោយយោងទៅនឹងកំណត់ហេតុនានានៃការប្រជុំជាច្រើនរបស់បក្សកុម្មុយនីសកម្ពុជា លោក កាណាវ៉ាស ស្នើថា ខ្លឹមសារនៃឯកសារទាំងនេះត្រូវចាត់ទុកជាភស្តុតាងដែលតម្រូវឲ្យមានការពិនិត្យដោយឯករាជ្យ ។ ស្តីពីប្រធានបទសម័យកម្ពុជាប្រជាធិបតេយ្យ លោក កាណាវ៉ាស ជំទាស់ទៅនឹងសុន្ទរកថាមួយដែលថ្លែងដោយ អៀង សារី នៅក្នុងពេលពិសារអាហារពេលល្ងាចទទួលស្វាមន៍ លោក ដានីញែល ប៊ីនស៊ីន ដែលមកទស្សនកិច្ចនៅកម្ពុជានៅខែមេសា ឆ្នាំ១៩៧៨ ។ លោកបានបន្ថែមទៀតថា លោកបាន"ហួហ្គល" ឈ្មោះលោក ប៊ីនស៊ីន បានរកឃើញថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ លោក ប៊ីនស៊ីន គឺជាមនុស្សត្រូវបានគេស្គាល់ថា ជាអ្នកដំណើរសិក្សានិងចូលចិត្តរបស់កុម្មុយនីសម្នាក់ នៅពេលដែលសព្វថ្ងៃនេះលោកបែរទៅជាអ្នកគាំទ្រមូលធននិយមវិញ ។ លោក កាណាវ៉ាស ហាក់ដូចជាមានការសប្បាយចិត្តក្នុងការកត់សម្គាល់ពីការផ្លាស់ប្តូរគំនិតរបស់លោក ប៊ីនស៊ីន នៅក្នុងភាពស្មោះត្រង់ក្នុងនយោបាយ ហើយសុំថា

ប្រសិនបើ សុន្ទរកថានេះត្រូវបានគេយកមកប្រើលោក ប៊ីនស៊ីន គួរតែត្រូវបានហៅឲ្យមកធ្វើជាសាក្សី ឬថា សុក្រិត្យភាពនៃសុន្ទរកថានោះគួរត្រូវធ្វើការត្រួតពិនិត្យដោយឡែក ។ លោក កាណាវ៉ាស ក៏បាន បញ្ចេញមតិលើឯកសារនានាដែលយកធ្វើជាភស្តុតាងនិង គឺត្រូវតែធ្វើការត្រួតពិនិត្យដោយឡែក មុន ពេលដែលអង្គជំនុំជម្រះអាចប្រើឯកសារទាំងនោះបាន ។

## ក្រុមមេធាវីការពារក្តី ខៀវ សំផន បញ្ចេញយោបល់លើឯកសារនានា

បន្ទាប់មក មេធាវី គង់ សំអុន បានបញ្ចេញយោបល់លើឯកសារ ក្នុងនាមក្រុមមេធាវីការពារក្តី ខៀវ សំផន ។ លោកចាប់ផ្តើមធ្វើការសន្និដ្ឋានដោយអះអាងថា អង្គជំនុំជម្រះបានទទួលយកឯកសារជាច្រើនដែលមិនជាប់ពាក់ព័ន្ធ ។ ដូចជាឯកសារជាបទសម្ភាសន៍ លោក គង់ សំអុន អះអាងថា វិធីតែមួយគត់ ដែលអាចផ្ទៀងផ្ទាត់ពីសុក្រិតភាព និងខ្លឹមសារនៃឯកសារបែបនេះបានគឺហៅភាគីពាក់ព័ន្ធនឹងបទសម្ភាសន៍មកតុលាការ ។ ក្រោយមក លោក គង់ សំអុន ធ្វើការសន្និដ្ឋានលម្អិតដោយអះអាងថាដំណើរការប្រមូលឯកសារធ្វើឡើងដោយភាពលម្អៀងប្រឆាំងនឹងជនជាប់ចោទ ។ នៅក្នុងពេលធ្វើសក្ខីកម្មនេះ លោកបញ្ជាក់ពីការជំទាស់របស់មេធាវីការពារក្តីទៅលើរាល់ឯកសារទាំងអស់ ដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកឲ្យនាមថា ជា«អង្គការលម្អៀង» ដែលស្វែងរកតែ «ភស្តុតាងដាក់បន្ទុក» ប៉ុណ្ណោះ ។

លោក គង់ សំអុន បន្ទាប់មកបដិសេធលើឯកសារជាច្រើនមុនពេលសម្រាកអាហារថ្ងៃត្រង់ ។

## នួន ជា លះបង់សិទ្ធិក្នុងការស្តាប់សវនការក្នុងម៉ោងពេលដូចសព្វដង

មុនពេលសម្រាកអាហារថ្ងៃត្រង់ មេធាវីការពារក្តី នួន ជា បានស្នើដូចសព្វដងថា នួន ជា សុំលះបង់សិទ្ធិចូលរួមស្តាប់សវនការ ដោយទៅស្តាប់សវនការពេលរសៀលតាមប្រពន្ធ័សោតទស្សន៍វិញ ។ ដូចសព្វដង ប្រធានអង្គជំនុំជម្រះបានអនុញ្ញាតការស្នើសុំនេះ ដោយទាមទារឲ្យដាក់ពាក្យសុំដែលមានហត្ថលេខារបស់ នួន ជា ។

## ក្រុមមេធាវីការពារក្តី ខៀវ សំផន បញ្ចប់ការតវ៉ាលើឯកសារមួយចំនួន

នៅក្នុងសវនការពេលរសៀលនេះ លោក គង់ សំអុន បន្តធ្វើការជំទាស់ទៅនឹងឯកសារមួយចំនួន ។ នៅក្នុងសក្ខីកម្មនេះ លោកស្នើឲ្យអង្គជំនុំជម្រះទទួលយកការផ្តល់ឲ្យដោយ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងពេលដែលលោកធ្វើសក្ខីកម្មផ្ទាល់មាត់នូវឯកសារច្បាប់ដើមជា

ច្រើនពីទង់បដិវត្តសម្រាប់ឲ្យ “អ៊ុំ នួន” ធ្វើការពិនិត្យ ។ ក្នុងការតវ៉ានេះ លោក គង់ សំអុន អះអាងថា អ្នកសម្ភាសន៍ត្រូវតែហៅឡើងសវនការ“មកតទល់”នឹងជនជាប់ចោទដើម្បីបញ្ជាក់ពីភាពជឿទុកចិត្តនៃឯកសារទាំងនោះ និង ធានាថាខ្លឹមសារនៃការបង្កើតឯកសារត្រូវបានដឹងឲ្យបានជាក់ច្បាស់ ។

## ព្រះរាជអាជ្ញាឆ្លើយតបទៅនឹងការជំទាស់

បន្ទាប់ពីលោក គង់ សំអុន បានបង្ហាញបីការជំទាស់របស់ក្រុមមេធាវីការពាររួចមក ខាងព្រះរាជអាជ្ញាបានត្រូវអនុញ្ញាតឲ្យឆ្លើយតបទៅនឹងការបដិសេធទាំងនោះ ។ ទោះជាយ៉ាងណាក្តី ការបង្ហាញរបស់ព្រះរាជាអាជ្ញាជាតិ ចាន់ ដារ៉ារស្មី មិនបានប៉ុន្មាននាទីផង តុលាការជួបប្រទះនឹងបញ្ហាបច្ចេកទេសខាងដំណើរការធ្វើបតិចរិកធ្វើឲ្យមានការពន្យាពេលដំណើរការនីតិវិធី ។ នៅពេលដែលដំណើរការចាប់ផ្តើមឡើងវិញ លោក ចាន់ ដារ៉ារស្មី ចាប់ផ្តើមបទបង្ហាញថ្មីពីការពិភាក្សា លើឯកសារនានាទាក់ទងនឹងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ ដោយយោងទៅលើសក្ខីកម្មកន្លងមករបស់នានា ។ ទោះជាយ៉ាងនេះក្តី កាណាវ៉ាស មេធាវីការពារក្តី អៀង សារី បានជំទាស់ ដោយអះអាងថា ព្រះរាជអាជ្ញាកំពុងតែផ្តល់យោបល់លើឯកសារមួយដែលក្រៅពីបញ្ជីឯកសារ៩៥ ដែលផ្តល់ដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៃ អ.វ.ត.ក ដែលជាហេតុនាំឲ្យមានការយល់ច្រឡំក្នុងសវនការ កាលពីព្រឹកមិញ ។ ជំទាស់មានប្រសិទ្ធិភាព ប្រធានអង្គជំនុំជម្រះបង្គាប់ព្រះរាជអាជ្ញាកំណត់ការសន្និដ្ឋានរបស់ខ្លួនឲ្យទាក់ទងនឹងឯកសារ៩៥ក្នុងបញ្ជីប៉ុណ្ណោះ ។ បន្ទាប់មក ចាន់ ដារ៉ារស្មី បន្ត និងផ្តល់ជូននូវការសង្ខេបពីឯកសារជាវីដេអូក្នុងបញ្ជី និង អះអាងថា រាល់វីដេអូបង្ហាញពីព័ត៌មានសំខាន់ និងអាចទុកចិត្តបាន ។ លោកក្រោយមក ជូនវេទិកានេះទៅ ហ្វាគុនី ដេបនេដ្ឋ តំណាងព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តធ្វើការសន្និដ្ឋានសម្រាប់ថ្ងៃនេះ ។

## តំណាងព្រះរាជាអាជ្ញាអន្តរជាតិ ហ្វាគុនី ដេបនេដ្ឋ ឆ្លើយតបទៅនឹងការជំទាស់នានារបស់មេធាវីការពារក្តី

ហ្វាគុនី ដេបនេដ្ឋ បានចាប់ផ្តើមដោយអះអាង ជាទូទៅក្រុមមេធាវីការពារលើកឡើងហួសពីតម្រូវការដែលទទួលយកបាននៅក្នុងកម្រិតអន្តរជាតិ ក្នុងសំអាងរបស់ពួកគេ ។ ឧទាហរណ៍ ដូចជាលោកស្រីបានកត់សម្គាល់ថា ក្រុមមេធាវីការពារសំអាងថា វាជាការចាំបាច់ត្រូវកោះហៅអ្នកធ្វើបទសម្ភាសន៍មកធ្វើជាសាក្សី មុនពេលទទួលយកបទសម្ភាសន៍នេះ លោកស្រីអះអាងថា ការលើកឡើងនេះ ហាក់ដូចជាចាកឆ្ងាយពីតម្រូវការក្នុងការទទួលស្គាល់ឯកសារមួយ ក្រោមទម្លាប់នៃយុត្តាធិការអន្តរ

ជាតិនោះ ។ បន្ទាប់មក លោកស្រី ដេបនេដ្ឋ អះអាងថា របបកម្ពុជាប្រជាធិបតេយ្យឯកសារ«ពាណិជ្ជកម្ម»គឺ ឯកសារពិត និងជឿជាក់បានពីព្រោះពួកគេបង្ហាញពីការរក្សាបញ្ជីរបស់បក្សកុម្មុយនីស្តកម្ពុជាជាប្រពន្ធ័ និងរួមបញ្ចូលទាំងកំណត់សម្គាល់នានាដែលមានរៀបរាប់ពីមន្ត្រីរបស់បក្សកុម្មុយនីសជាច្រើន ដូចជា វ៉ាន់ រិទ្ធ ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកលោកស្រី ដេបនេដ្ឋ ពិភាក្សាឯកសារនានាបានពីរដ្ឋាភិបាលបារាំង និង អេស.ប៊ី.អាយ ដោយអះអាងថា ទាំងនោះជាញឹកញាប់ប្រទាក់ប្រទងពីមួយទៅមួយ ហើយអះអាងថា រាល់ឯកសារទាំងអស់សុទ្ធតែសុក្រិត្យត្រឹមត្រូវ និងអាចទុកចិត្តបាន ។ នៅក្នុងពេលនោះ តំណាងព្រះអាជ្ញាបានរៀបរាប់ពីរូបភាពពិត និងការកត់សម្គាល់ផ្លូវការដែលឃើញមានក្នុងឯកសារជាច្រើនដែលបានធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជា ។

លោកស្រី ដេបនេដ្ឋ ក៏បានរៀបរាប់ពី ឯកសារនានាដែលបានរៀបរាប់ពីការចាប់ខ្លួនរបស់ ហ៊ូ នឹម និងការបញ្ជូនលោកទៅកាន់មន្ទីរសន្តិសុខទួលស្លែងដើម្បីធ្វើទារុណកម្ម និងសម្លាប់ជាមួយនិងចម្លើយសារភាពពិតរបស់ ហ៊ូ នឹម ។ ទាក់ទងនឹងចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម លោកស្រី ដេបនេដ្ឋបានលើកឡើងថាវាបញ្ជាក់ថា ហ៊ូ នឹម ត្រូវបានបញ្ជូនទៅគុកនិងធ្វើទារុណកម្ម ។

លោកស្រីបានកត់សម្គាល់ផងដែរថា ចម្លើយសារភាពនោះរួមមានការសរសេរកំណត់សម្គាល់ដោយលេខាគុក ឌុច ដែលបញ្ជាក់ថា មានមន្ត្រីបក្សកុម្មុយនីសផ្សេងទៀតទទួលសារភាព ។ លោកស្រីសន្និដ្ឋានថា ប្រភេទភស្តុតាងទាំងអស់នេះគួរតែត្រូវទទួលយកដោយករណីលើកលែងដោយថា ជាទូទៅត្រូវមិន ទទួលស្គាល់ចាត់ថាជាភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ។ លោកស្រី ដេបនេដ្ឋ ក៏បានពិភាក្សា បីការវិភាគពីចម្លើយសារភាពនានាសរសេរដោយមន្ត្រីគុក ប៉ុន ដែលលោកស្រីអះអាងថា “បានភ្ជាប់ចម្លើយសារភាពជាច្រើនជាមួយនឹងរឿងរ៉ាវដែលទាក់ទងគ្នាយ៉ាងច្រើនអស្ចារ្យ” ។ បន្ទាប់ពីពិភាក្សា ឯកសារនានានៅទួលស្លែង តំណាងព្រះរាជអាជ្ញាបែរទៅឯកសាររបស់ ស៊ីវ ហេឌី ហើយអះអាងថា ឯកសារទាំងនេះគឺវាសមរម្យនឹងទទួលយក ។ លោកស្រី ដេបនេដ្ឋ បានជម្រាបអង្គជំនុំជម្រះថា ស៊ីវ ហេឌី ឈប់បម្រើការងារឲ្យការិយាល័យសហព្រះរាជអាជ្ញាមុនពេលនឹងការដាក់ជូនឯកសារដោយយោងទៅលើឯកសារនានាដែលលោកបានព្រៀងឡើង ហេតុដូចនេះ លោកមិនអាចមានលទ្ធភាពមកសរសេរព្រៀងឯកសារដាក់ជូនទាំងនេះទេ ។

បន្ទាប់មក លោកស្រីមិនបានធ្វើការផ្តល់ជាយោបល់ទាក់ទងនឹងការប្រើការថ្លែងនានារបស់សាក្សីដែលមិនបានប្រមូលដោយសហចៅក្រមស៊ើបអង្កេត ដែលក្រុមមេធាវីការពារក្តីបានបដិសេធជំទាស់នោះទេ ដោយថ្លែងថា រៀបរាប់របស់សាក្សីនានាមិនគួរត្រូវជាប្រធានបទដដែកពិភាក្សាសម្រាប់ថ្ងៃនេះទេ ។

លោកស្រី ដេបនេដ្ឋ ក៏បានលើកឡើងផងដែរថា ក្រុមការពារក្ដីរបស់ នួន ជា បានព្យាយាមប្រើការថ្លែងរបស់សាក្សីនានាដែលជាមន្ត្រីរាជការសព្វថ្ងៃដូចដែលបានធ្វើក្នុងការឡើងមុនៗ ។

បន្ទាប់មក តំណាងព្រះរាជអាជ្ញាអះអាងថា ឯកសារជាក់ស្ដែងមួយចំនួនដែលបានជំទាស់ដោយក្រុមការពារក្ដីនោះ រាល់ឯកសារទាំងនោះសុទ្ធតែមានលក្ខណៈសុក្រិតភាពគ្រប់គ្រាន់ និងការអាចជឿជាក់បានដែលត្រូវទទួលស្គាល់ជាជាងបដិសេធ ។

## ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងឯកសារដែលតវ៉ាដោយក្រុមមេធាវីការពារ

បន្ទាប់ពីបញ្ចប់ការបង្ហាញរបស់ព្រះរាជអាជ្ញាវេទិកានេះ ត្រូវប្រគល់ឲ្យទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើការសន្និដ្ឋានផ្សេងៗ ។ លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត បានលើកឡើងថា ក្រុម មេធាវីការពារបានជំទាស់ទៅនឹងបណ្ដុំឯកសារនានាដែលបានត្រូវចាត់ថា «បានពិនិត្យយ៉ាងគ្រប់ជ្រុងជ្រោយ» ដោយចៅក្រមប្រកបដោយជំនាញវិជ្ជាជីវៈជាច្រើននិងដូចនេះគួរតែគិតថា សមល្មមនឹងអាចទទួលស្គាល់ ។ លោកស្រីក៏បានកត់សម្គាល់ផងដែរថាការជំទាស់នានាប៉ុន្មានថ្ងៃមកនេះត្រូវបានលើកឡើងនិងដោះស្រាយកាលពីសវនកាលមុនៗ ។ ចុងបញ្ចប់លោកស្រីអេលីហ្សាបេត ស៊ីម៉ុនណូហ្វត ក៏បានផ្ដល់យោបល់លើសន្និសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលគួរតែត្រូវបានអនុវត្តឲ្យបានហ្មត់ចត់ដោយអង្គជំនុំជម្រះដើម្បីធានាថា ការហាមប្រាមឯកសារទាក់ទងនឹងការធ្វើទារុណកម្មមិនត្រូវធ្វើឲ្យអន់ថយដោយ អ.វ.ត.ក ។

## ការឆ្លើយតបរបស់ក្រុមមេធាវីការពារ នួន ជា ទៅកាន់ការផ្ដល់យោបល់លើការប្រើការ រៀបរាប់របស់សាក្សីនានា

បន្ទាប់មក អង្គជំនុំជម្រះបានកត់សម្គាល់ថា វាមានពេលវេលាសស់តិចណាស់ ហើយអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដី នួន ជា ធ្វើការកត់សម្គាល់លើការកត់សម្គាល់របស់តំណាងព្រះរាជអាជ្ញា ទាក់ទងនឹងការលើកឡើងរបស់ក្រុមការពារទាក់ទងនឹងការប្រើសេចក្ដីថ្លែងការរបស់សាក្សីនានាពីមន្ត្រីរាជការបួននាក់ដែលបម្រើការងារសព្វថ្ងៃ ។ បន្ទាប់មក លោក អៀនុហ្សី បានបញ្ជាក់ថា ក្រុមមេធាវីការពារ នួន ជា គ្រាន់តែជំទាស់ទៅនឹងការប្រើសេចក្ដីថ្លែងការនានា «ដើម្បីបញ្ជាក់ពីសកម្មភាពនានា ឬការប្រព្រឹត្តរបស់ជនជាប់ចោទ ឬកត្តានាំឲ្យបញ្ហានានានៅក្នុងសំណុំរឿងដោយមិនមែនបុគ្គលនានាមានមុខក្នុងការធ្វើការសួរដេញដោលផ្ទៀងផ្ទាត់តែប៉ុណ្ណោះ» ។ ជាការពិតណាស់ លោក អៀនុហ្សី លើកឡើងថាក្រុមមេធាវីការពារក្ដី នួន ជា បានស្នើរួចមកហើយឲ្យមានការធ្វើសក្ខីកម្មពីបុគ្គលទាំងនេះ ។ បន្ទាប់ពី

ការសន្និដ្ឋាននេះ ប្រធានអង្គជំនុំជម្រះ និល ណុន ប្រកាសពីថ្ងៃដែលពន្យារពេលសវនការ ។ លោកប្រធានក៏បានកត់សម្គាល់ផងដែរពីដំណើរនីតិវិធីសំណុំរឿង០០២ នឹងផ្អាករហូតដល់ថ្ងៃទី១២ ខែមិនា នីតិវិធីនឹងបន្តការងារឡើងវិញនៅវេលាម៉ោង ៩ព្រឹក ។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការផ្អាកនេះ និងការអភិវឌ្ឍន៍នៃសំណុំ០០២មាននៅក្នុងគេហពទំព័ររបស់ អ.វ.ត.ក ។

ការកែតម្រូវៈ នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១២ ពេលដែលគេហទំព័ររបស់កម្ពុជាឃ្លាំមើលសវនការបានដាក់ព័ត៌មានថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់វីដេវូបទសម្ភាសជាមួយជនជាប់ចោទ ខៀវ សំផន ជូនតុលាការនោះដែលដកស្រង់ចេញពីកុនឯកសារប្រឈមនឹងអំពើប្រល័យពូជសាសន៍នោះជាការណ៍មិនត្រឹមត្រូវទេ ។ វីដេអូឌីបបីដំបូងគឺដកស្រង់ចេញពីកុនចំណាងជើងការថារស់រានមានជីវិត ៖ ក្នុងកណ្តាលចំណោមពួកខ្មែរក្រហមឆ្កួតលេលា ។ វីដេអូឌីចុងក្រោយដែលបង្ហាញដោយដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវដកស្រង់ចេញពីការប្រឈមនឹងអំពើប្រល័យពូជសាសន៍ ។

**-ចប់-**